**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## សូមគោរពជូន
## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ទេសរដ្ឋមន្ត្រី ឱម យ៉ិនទៀង និងលោកជំទាវ មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ឡុង វិសាខា យ៉ិនទៀង ព្រមទាំងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ជីដា** បានទទួលមរណភាព កាលពីថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៧:០៥ នាទីព្រឹក ម៉ោងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ត្រូវនឹងម៉ោង ១៣:០៥ ម៉ោងនៅកម្ពុជា ក្នុងជន្មាយុ ៩៤ឆ្នាំ ដោយជរាពាធ។

ក្នុងវេលាប្រកបដោយក្តីជ្រួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុតជាមួយ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ទេសរដ្ឋមន្ត្រី និងលោកជំទាវមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ជីដា** ដែលជាម្តាយបង្កើត ម្តាយក្មេក ជីដូន និងជាជីដូនទួត ដែលប្រកបដោយព្រហ្មវិហារធម៌ ហើយក៏ជាការបាត់បង់នូវមហាកម្លាំងសាមគ្គីនៅក្នុងចលនាពុទ្ធសាសនូបត្ថម្ភក៍ផងដែរ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខ័ន្ធ **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ជីដា** សូមអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ទេសរដ្ឋមន្ត្រី និងលោកជំទាវមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ៕

ថ្ងៃ ចន្ទ ១៥កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២២
**រដ្ឋមន្ត្រី**

**ព្រំ-សុខា**